Summary of Civil Case Judgement

Federal States of Micronesia
(*People of Rull ex rel. Ruepong v. M/V Kyowa Violet*, 14 FSM Intrm. 403 (Yap 2006))

**អង្គហេតុ៖** ឆ្នាំ២០០៤ កប៉ាល់ឈ្មោះ Kyowa Violet ដោតទង់ជាតិប្រទេសប៉ាណាម៉ា និងមានជនជាតិកូរ៉េជានាវិក បានបើកចូលក្នុងដែនទឹករបស់រដ្ឋ Yab នៃរដ្ឋសហព័ន្ធ Micronesia ប៉ះថ្មប៉ប្រះទឹក (reef) និងធ្លាយប្រេងចូលទឹកសមុទ្រ ប៉ះដល់បរិស្ថាន ការនេសាទ ព្រមទាំងការប្រើប្រាស់ទឹកសមុទ្រ។ សហគម Tabinaw របស់នៅក្បែរសមុទ្រនៃរដ្ឋ Yab បានទទួលការរងគ្រោះ និងការខូចខាត (damages)។

**បណ្ដឹងនិងសម្រេច៖** សហគមនេះ បានប្ដឹងរួម (class actions) ដែលត្រូវទទួលស្គាល់ដោយតុលាការ (កំណត់តាមច្បាប់) ដើម្បីទាមទារសំណង។ ចុងចម្លើយម្ចាស់នាវា បានតវ៉ាថា សហគមនេះមិនមានឋានៈក្នុងការប្ដឹងទេ (standing to sue)។ នេះក្នុងន័យថាមានតែ រដ្ឋ Yab ទេដែលមានសិទ្ធិប្ដឹង។ តុលាការយល់ថា សហគម មានចំណែកសិទ្ធិលើសមុទ្រ ដូចនេះអាចប្ដឹងបាន (សិទ្ធិប្រពៃណី)។ តុលាការអះអាងថា ម្ចាស់បណ្ដឹង ជាម្ចាស់លើធនធានធម្មជាតិ និងមានសិទ្ធិផ្ដាច់មុខក្នុងការប្រើប្រាស់និងធ្វើអាជីវកម្មធនធានសមុទ្រ នៃតំបន់ប៉ះពាល់ដោយនាវាបុកថ្មនិងធ្លាយប្រេង។ ម្ចាស់បណ្ដឹង បានផ្អែកលើអំពើអនីត្យានុកូលសមុទ្រ (maritime tort)។ តាមធាតុផ្សំនៃ tort តុលាការរកឃើញថា នាវាមានករណីកិច្ច (duty) បានបំពានករណីនេះ (breach) បង្កជាការខូចខាត (causation to damage)។ តុលាការអះអាងថា៖ នាវា Violet បានបំពានករណីកិច្ចនាវាចរប្រកបដោយសុវត្ថិភាព ដែលបំពាននេះបង្កជាការធ្លាយប្រេង ខូចខាតដល់ធនធានសមុទ្រ។ ម្ចាស់បណ្ដឹងបាន មានបន្ទុកដាក់ភស្ដុតាង (burden of proof) បង្ហាញចំណងហេតុនិងផល ដែលជាមូលហេតុ កៀកកិត (proximate cause)។

ពាក់ព័ន្ធសំណងការខូចខាត តុលាការតម្រូវថា ចំនួនទាមទារត្រូវតែជាក់លាក់និងសមហេតុផល (reasonable certainty)។ ម្ចាស់បណ្ដឹងអះអាងថា ការខូចខាតដល់ថ្មក្នុងទំហំ ១៤៣៦ ម៉ែត្រការ៉េ និងប្រេងប៉ះពាល់ដល់ដើមកោងកាង ប្រមាណ១៥៤០៦ ម៉ែត្រក្រឡា...។ តុលាការសម្រេចលើសំណងគិតជាម៉ែត្រក្រឡា និងតាមកម្រិតនៃការខូចខាត (ទទួលការលេចប្រេងខ្លាំងឬតិចក្នុងតំបន់នោះ) ។ ដូចជា ៦០០ ដុល្លាក្នុង១ ម៉ែត្រក្រឡា។ បន្ថែមពីលើនេះ បានផ្ដល់ជាងមួយលានដុល្លាសម្រាប់ការខូចខាតធនធានសមុទ្រ ចំនួនជាងប្រមាណ២០មឺនដុល្លាសម្រាប់ការខកខានហែលទឹក (ជាតិប្រេងក្នុងទឹក) សម្រាប់មនុស្សជាង២ពាន់នាក់។ សូមបញ្ជាក់ថា ម្ចាស់នាវាបានចូលរួមសម្អាតប្រេងដែលលេចផងដែរ។ ជាចុងក្រោយ តុលាការបានតម្រូវឲ្យម្ចាស់នាវាបន្តតាមដានការអនុវត្ត ការសម្អាតប្រេង ក្នុងអំលុង៦ខែបន្ត និងរាយការណ៍ជូនតុលាការ។

**កំណត់សំគាល់៖** ក. អង្គហេតុបុកថ្ម និងឆ្លាយប្រេង បង្កបញ្ហាបរិស្ថាន ខូចខាតច្រើន ហើយដើមបណ្ដឹងបានប្ដឹងទាមទារសំណងច្រើនប្រភេទ ដូចជា ការរំខានសាធារណៈនិងឯកជន (public and private nuance)។ **ខ**. ជនបង្ករ ត្រូវតែទទួលខុសត្រូវ ដើម្បីការពារធនធានសមុទ្រ។